# សេចក្តីថ្លែងការណ៍រួម
# អង្គការសង្គមស៊ីវិលសូមអំពាវនាវឲ្យដោះលែងអ្នកការពារសិទ្ធិដីធ្លីទាំង ១២ នាក់ដែលត្រូវជាប់ពន្ធនាគារ ដោយសារការអនុវត្តសេរីភាពមូលដ្ឋាន

ថ្ងៃទី៦ ខែមីនា ឆ្នាំ២០១៥ មុនទិវានារីអន្តរជាតិនៅថ្ងៃទី ៨ ខែមីនា យើងខ្ញុំជាក្រុមអង្គការសង្គមស៊ីវិលមានរាយនាមដូចខាងក្រោម សូមអំពាវនាវឲ្យមានការដោះលែងសកម្មជនបឹងកក់ជាបន្ទាន់ រួមមាន ទេព វន្នី ង៉ែត យុន, សុង ស្រីលាភ, គង់ ចន្ថា, ផាន់ ឈុនរ៉េត, បូ ឆវី, នង ស្រេង, ហេង ពេជ្រ, អ៊ឹម ស្រីទូច, ភួង សុភាព ព្រះតេជគុណ សឿង ហាយ និងអ្នកការពារសិទ្ធិលំនៅដ្ឋាន លី ស៊ីវមិញ។ អ្នកទាំង ១២ នាក់ត្រូវបានឃុំខ្លួនដោយសារតែការអនុវត្តសេរីភាពមូលដ្ឋានរបស់ខ្លួន នៅក្នុងជម្លោះដីធ្លីដ៏រ៉ាំរ៉ៃក្នុងតំបន់បឹងកក់ នៅទីក្រុងភ្នំពេញ។

កាលពីថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៤ ង៉ែត យុន, ទេព វន្នី, សុង ស្រីលាភ, គង់ ចន្ថា, ផាន់ ឈុនរ៉េត, បូ ឆវី និង នង ស្រេង ត្រូវបានចាប់ខ្លួន ដោយចោទប្រកាន់ពីបទរារាំងចរាចរណ៍សាធារណៈ ហើយត្រូវបានកាត់និងផ្តន្ទាទោសក្នុងរយៈពេល ៣៦ ម៉ោង ដោយទទួលទោសជាប់ពន្ធនាគារអតិបរមារយៈពេល ១ ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៥០០ ដុល្លារសហរដ្ឋអាមេរិក។[1] ស្ត្រីទាំង ៧ នាក់ បានធ្វើបាតុកម្មប្រឆាំងតវ៉ា ដើម្បីឲ្យអាជ្ញាធរចាត់វិធានការចំពោះបញ្ហាទឹកលិចនៅក្នុងសហគមន៍របស់គាត់។ តំបន់នេះរងគ្រោះដោយសារទឹកលិចតាំងពីឆ្នាំ ២០០៨ នៅពេលមានការចាក់ខ្សាច់បំពេញបឹង ដោយក្រុមហ៊ុន ស៊ូកាគូ អ៊ីន។ មានស្ត្រី ៣ នាក់ និងព្រះសង្ឃមួយអង្គ បន្ថែមទៀត ត្រូវប្រឈមមុខនឹងហេតុការណ៍ស្រដៀងគ្នានៅថ្ងៃបន្ទាប់ ដោយត្រូវឃុំខ្លួន ខណៈពេលធ្វើការប្រឆាំងតវ៉ាដោយសន្តិវិធីនៅក្រៅតុលាការ ដើម្បីទាមទារឲ្យមានការដោះលែងសកម្មជនដទៃទៀត ហើយក្រោយមកក៏ត្រូវបានផ្តន្ទាទោសពីបទប្រឆាំងមន្ត្រីរាជការសាធារណៈ។ នៅថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៥ ស្របពេលដែលមានការបន្ថយទោសតិចតួចដល់ជនជាប់ចោទ សាលាឧទ្ធរណ៍បានតម្កល់ទោសរបស់ពួកគាត់ ដែលសម្រេចដោយនីតិវិធីមិនត្រឹមត្រូវតាមស្តង់ដារសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។[2]

នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤ កញ្ញា លី ស៊ីវមិញ ត្រូវបានចាប់ខ្លួនជាមួយនឹងឪពុក គឺលោក លី ស្រ៊ាខេង ក្នុងបរិបទជម្លោះដីធ្លីជាមួយក្រុមហ៊ុន យុន សៀ អ៊ឹមផត អ៊ិចផត បន្ទាប់ពីពួកគេមិនព្រមចាកចេញពីទីតាំងដីមានជម្លោះនៅតំបន់បឹងកក់១ ។ ក្រុមគ្រួសារនេះរងការគំរាមកំហែងសម្លាប់ ការវាយប្រហារដោយហិង្សា និងការសម្លុតបំភ័យ។ លោក ខេង ត្រូវបានអនុញ្ញាតឲ្យនៅក្រៅឃុំនៅថ្ងៃទី៥ ខែធ្នូ ប៉ុន្តែតុលាការបានបដិសេធសំណើសុំនៅក្រៅឃុំរបស់កញ្ញា សៀវមិញ នៅថ្ងៃទី៥ ខែមករា ដោយសំអាងលើហេតុផលការពារការប្រព្រឹត្តបទល្មើសបន្ថែមទៀត ការបំផ្លាញភស្តុតាង ឬគំរាមកំហែងសាក្សីដោយពុំមានការពន្យល់ពីមូលហេតុ

[1] ម.ស.ម.ក ‘សមាជិកសហគមន៍បឹងកក់ត្រូវបានចាប់ខ្លួន ឃុំខ្លួន និងផ្តន្ទាទោសក្នុងរយៈពេល ៣៦ ម៉ោង’ (ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៤), http://bit.ly/15M7uOu.

[2] សេចក្តីថ្លែងការណ៍រួម របស់អង្គការសង្គមស៊ីវិល ‘ការចាប់ខ្លួនតាមអំពើចិត្តនៅក្នុងតំបន់បឹងកក់ ១’ (ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៤), http://www.cchrcambodia.org/index_old.php?url=project_page/project_page.php&p=press_detail.php&pro=LR&pro_id=12&prid=524&id=3; សេចក្តីថ្លែងការណ៍រួម របស់អង្គការសង្គមស៊ីវិល ‘ក្រុមសង្គមស៊ីវិលថ្កោលទោសការឃុំខ្លួនជាបន្តរបស់សកម្មជនទាំង ១១ នាក់’ (ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៥, http://www.cchrcambodia.org/index_old.php?url=media/media.php&p=press_detail.php&prid=533&id=5&lang=eng

ដែលហានិភ័យបែបនេះអាចកើតឡើងក្នុងរឿងនេះទេ។[3] នាងត្រូវបានចោទប្រកាន់ពីបទប្រើអំពើហិង្សាប្រឆាំងលើសិទ្ធិកាន់កាប់អចលនវត្ថុដោយសុចរិត។ ស្របពេលដែលនាងកំពុងតែស្ថិតនៅក្នុងការឃុំខ្លួនបណ្ដោះអាសន្នតាំងពីពេលនោះ សវនាការរបស់នាងមិនទាន់ត្រូវបានកំណត់ពេលនៅឡើយទេ។

យោងតាមរដ្ឋធម្មនុញ្ញ កម្ពុជា *"ត្រូវទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញ អង្គការសហប្រជាជាតិ សេចក្ដីប្រកាសជាសាកលស្ដីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយដែលទាក់ទងនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ"*។ រដ្ឋធម្មនុញ្ញក៏បានចែងពីឯករាជ្យភាពនៃប្រព័ន្ធតុលាការ និងកំណត់ពីតួនាទីរបស់តុលាការថាដើម្បី *"ធានារក្សាអនាគតិ និងការពារសិទ្ធិ សេរីភាពរបស់ប្រជាពលរដ្ឋ"*។ ជាងនេះទៅទៀត ក្រុមប្រឹក្សាធម្មនុញ្ញរបស់កម្ពុជាបានបញ្ជាក់ថា *"កតិកាសញ្ញាអន្តរជាតិដែលកម្ពុជាទទួលស្គាល់"* ក្លាយទៅជាច្បាប់ ដែលចៅក្រមជំនុំជម្រះត្រូវតែគោរពតាម។ អ្នកជាប់ឃុំទាំង ១២ នាក់ ពុំបានទទួលការការពារទាំងអស់នេះទេ ដែលពួកគាត់ត្រូវបានដាក់ពន្ធនាគារដោយសារតែការអនុវត្តសិទ្ធិសេរីភាពខាងការបញ្ចេញមតិ និងសេរីភាពខាងការប្រមូលផ្ដុំដោយសន្តិវិធី។

មនុស្ស ១១ នាក់ ក្នុងចំណោមអ្នកទាំង ១២ គឺជាស្ត្រី។ យោងតាមការអនុម័តថ្មីៗ ទៅលើសេចក្ដីសម្រេចស្ដីពីស្ត្រីអ្នកការពារសិទ្ធិមនុស្សរបស់មហាសន្និបាតអង្គការសហប្រជាជាតិ បង្ហាញថា ស្ត្រីដែលធ្វើការការពារសិទ្ធិមនុស្ស ជួបប្រទះហានិភ័យ និងការប្រឈម ដែលតម្រូវឲ្យមានការយកចិត្តទុកដាក់ និងការការពារជាក់លាក់។[4] ក្នុងទិវានារីអន្តរជាតិ ដែលនឹងប្រារព្ធឡើងក្នុងសប្ដាហ៍នេះ គឺជាឱកាសដ៏ល្អបំផុតសម្រាប់រដ្ឋាភិបាល ដើម្បីបង្កើនភាពជឿជាក់ពីសំណាក់សហគមន៍អន្តរជាតិ ដោយទទួលស្គាល់សារៈសំខាន់ និងភាពស្របច្បាប់នៃអ្នកការពារសិទ្ធិមនុស្ស ជាពិសេសអ្នកការពារសិទ្ធិមនុស្សដែលជាស្ត្រីក្នុងការលើកកម្ពស់ និងការការពារសិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋនៅកម្ពុជា។

ពេលនេះគឺជាឱកាសដ៏ល្អសម្រាប់រដ្ឋាភិបាល ដើម្បីបង្ហាញពីការប្ដេជ្ញាចិត្តដ៏ខ្លាំងក្លាក្នុងការគោរពសិទ្ធិមនុស្ស ដូចគ្នានឹងការប្ដេជ្ញាចិត្តថ្មីៗនេះនៅចំពោះមុខសហគមន៍អន្តរជាតិ ក្នុងអំឡុងការត្រួតពិនិត្យជាសាកលតាមពេលវេលាកំណត់នៅក្នុងក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិនៅឆ្នាំ២០១៤ និងមុនពេលដែលកម្ពុជានឹងត្រូវត្រួតពិនិត្យជាលើកទីពីរនៅចំពោះមុខក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិនៅថ្ងៃទី១៧ និង ១៨ ខែមីនានាពេលខាងមុខនេះ។ ការស្ទាក់ស្ទើររបស់រដ្ឋាភិបាលក្នុងការការពារសិទ្ធិអ្នកការពារសិទ្ធិមនុស្ស និងសកម្មភាពរបស់រដ្ឋាភិបាលក្នុងការរឹតត្បិតសិទ្ធិ ក្នុងការលើកកម្ពស់ និងទាមទារដើម្បីឲ្យមានការការពារ និងទទួលស្គាល់សិទ្ធិមនុស្ស បានឆ្លុះបញ្ចាំងពីការរំលោភបំពានលើកាតព្វកិច្ចរបស់រដ្ឋដែលនេះមិនអាចទទួលយកបានបន្តទៀតនោះទេ។ ស្របពេលនឹងការបញ្ឈប់ការប្រើប្រាស់តុលាការ ក្នុងការយាយីសកម្មជន និងអ្នកការពារសិទ្ធិមនុស្ស អាជ្ញាធរថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានគួរតែចាត់វិធានការឲ្យបានម៉ត់ចត់ក្នុងការដោះស្រាយជម្លោះដីធ្លី និងរកដំណោះស្រាយដែលគោរពសិទ្ធិរបស់ភាគីទាំងអស់ ជាជាងការបិទសំឡេងជនងាយរងគ្រោះ និងជននៅជាប់ស្រយាល ហើយបន្តធ្វើឲ្យជម្លោះកាន់តែរីករាលដាលថែមទៀត។

[3] សេចក្ដីថ្លែងការណ៍រួម របស់អង្គការសង្គមស៊ីវិល 'ការចាប់ខ្លួនតាមអំពើចិត្តនៅក្នុងតំបន់បឹងកក់ ១' (ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៤) <http://cchrcambodia.org/index_old.php?url=media/media.php&p=press_detail.php&prid=524&id=5>

[4] http://www.un.org/en/ga/search/view_doc.asp?symbol=A/RES/68/181

យើងខ្ញុំជាក្រុមអង្គការសង្គមស៊ីវិលដែលបានរាយនាមដូចខាងក្រោម សូមអំពាវនាវឲ្យមានការដោះលែងជាបន្ទាន់ដល់អ្នកជាប់ឃុំទាំង ១២ នាក់ និងទម្លាក់រាល់ការចោទប្រកាន់ទាំងអស់ទៅលើពួកគាត់។ យើងនឹងប្រមូលសារគាំទ្រពីសាធារណជន ដើម្បីផ្ញើទៅកាន់ជនជាប់ឃុំទាំងអស់ជារៀងរាល់ខែ។ យើងនឹងបន្តយុទ្ធនាការទាមទារសិទ្ធិរបស់ពួកគាត់ រហូតទាល់តែអ្នកទាំង ១២ ត្រូវបានដោះលែង។

**ដោះលែងអ្នកទាំង ១២!**

១. បន្ទាយស្រី

២. សហគមន៍បឹងកក់ (BKL)

៣. សហគមន៍បឹងឈូក (BCC)

៤. សហគមន៍បឹងត្របែក (BTC)

៥. សហគមន៍បុរីកីឡា (BK)

៦. អង្គការអភិវឌ្ឍន៍សំលេងសហគមន៍ (BCV)

៧. សម្ព័ន្ធសហជីពកម្ពុជា (CATU)

៨. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក)

៩. គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃអង្គការ សមាគមការពារសិទ្ធិមនុស្សកម្ពុជា (CHRAC)

១០. សមាគមការពារសិទ្ធិមនុស្ស និងការអភិវឌ្ឍន៍នៅកម្ពុជា (ADHOC)

១១. សហភាពការងារកម្ពុជា (CLC)

១២. អង្គការកម្ពុជាដើម្បីកុមារ និង ការអភិវឌ្ឍន៍ (COCD)

១៣. សម្ព័ន្ធសហគមន៍កសិករកម្ពុជា (CCFC)

១៤. គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (COMFREL)

១៥. មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍(CLEC)

១៦. គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC)

១៧. អង្គការសមធម៌កម្ពុជា (EC)

១៨. អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា (GADC)

១៩. ក្រុមការងារពិសេសសិទ្ធិលំនៅឋាន (HRTF)

២០. សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA)

២១. អង្គការឃ្លាំមើលសិទ្ធិមេធាវី កាណាដា (LRWC)

២២. អង្គការជំនួយផ្លូវច្បាប់ដល់កុមារ និងស្ត្រី (LSCW)

២៣. អង្គការលើកស្ទួយប្រជាពលរដ្ឋ (PIO)

២៤. សមាគមធាងត្នោត (STT)

២៥. អង្គការសីលការ

២៦. សហគមន៍ SOS អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ

២៧. អង្គការស្តារកម្ពុជា
២៨. អង្គការស្ត្រីខ្មែរ
២៩. សហាគមន៍ថ្មដា (TDC)
៣០. ក្រុមការងារដើម្បីដោះស្រាយទំនាស់ (ACT)

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងកញ្ញា ឆាយ ឈុនលី អ្នកសម្របសម្រួលគម្រោងការពារសេរីភាពមូលដ្ឋានតាមរយៈទូរសព្ទលេខ +៨៥៥(០) ១៧ ៥២ ៨០ ២១ ឬ អ៊ីម៉ែល chhunly.chhay@cchrcambodia.org ឬ លោក វណ្ណ សូផាត អ្នកសម្របសម្រួលគម្រោងកំណែទម្រង់ដីធ្លីតាមរយៈទូរសព្ទលេខ +៨៥៥(០) ១២ ៩៤ ១២ ០៦ ឬ អ៊ីម៉ែល vann.sophath@cchrcambodia.org